**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ៩ ខែមិថុនាឆ្នាំ ២០២០
ទំនាក់ទំនង៖ Alejandra (Alex) Basquez, Director, Department of Human Resources (
មន្ទីរធនធានមនុស្ស), 562.570.6140, Alex.Basquez@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ប្រធានមន្ទីរសាធារណការលោក Craig Beck នឹងចូលនិវត្តន៍



ទីក្រុងឡុងប៊ិចបានប្រកាសនៅថ្ងៃនេះពីការចូលនិវត្តន៍របស់ប្រធានមន្ទីរសាធារណការលោក Craig Beck។ លោក Craig Beck បានចូលធ្វើការជាមួយទីក្រុងនេះជិត ៣៤ ឆ្នាំមកហើយចាប់តាំងពីថ្ងៃទី ៨ ខែកក្កដាឆ្នាំ ១៩៨៦ ។

លោក Tom Modica ប្រធានគ្រប់គ្រងក្រុងបានមានប្រសាសន៍ថា "កេរ្តិ៍ដំណែលរបស់ Craig គឺស្ថិតនៅជុំវិញយើងនៅក្នុងទីក្រុងនេះចាប់ពីអគារស៊ីវិលដ៏ទំនើបរបស់យើងរហូតដល់ការអភិវឌ្ឍថ្មីៗនៅទូទាំងឡុងប៊ិចនិងការអភិវឌ្ឍនៅតាមសមុទ្រផងដែរ។ យើងសូមថ្លែងអំណរគុណចំពោះចំណង់ចំណូលចិត្តរបស់ Craig ក្នុងការបម្រើនិងសម្រាប់ការផ្លាស់ប្តូរប្រកបដោយភាពច្នៃប្រឌិតដែលគាត់បានផ្តល់ដល់សហគមន៍ឡុងប៊ិច។"

ការងារដំបូងរបស់លោក Craig Beck នៅក្នុងទីក្រុងគឺជាអ្នកទំនាក់ទំនងខាងផ្នែកពន្លត់អគ្គីភ័យដែលបានឆ្លើយតបការហៅចូលនៃលេខទូរសព្ទ័បន្ទាន់ ៩-១-១។ បន្ទាប់មកគាត់បានប្តូរទៅធ្វើនៅមន្ទីរអភិវឌ្ឍន៍សហគមន៍ហើយផ្តល់សេវាកម្មដល់ប្រជាជនដែលមានចំណូលទាបនិងគាំទ្រដល់អង្គការមិនរកប្រាក់ចំណេញសហគមន៍បន្ទាប់ពីភាពចលាចលស៊ីវិលដែលកើតឡើងនៅឆ្នាំ ១៩៩២ នៅឡុងប៊ិច។ ក្រោយមកលោក Beck បានគ្រប់គ្រងមូលនិធិអភិវឌ្ឍន៍សហគមន៍ក្នុងទីក្រុងនិងប្រាក់កម្ចីចំនួន ៤0 លានដុល្លារដែលទីក្រុងបានទទួលសម្រាប់ការអភិវឌ្ឍនៃឆ្នេរ Queensway Bay និង The Pike។ លោក Beck បានត្រួតពិនិត្យថវិកាអភិវឌ្ឍន៍សហគមន៍ហើយក្រោយមកបានអនុវត្តការទិញទ្រព្យសម្បត្តិជាច្រើនដែលបានក្លាយជាផ្នែកមួយនៃការអភិវឌ្ឍន៍បច្ចុប្បន្ននិងអនាគតរបស់ទីក្រុង។

ក្នុងនាមជាប្រធានផ្នែកសេវាកម្មអភិវឌ្ឍន៍លោក Beck បានចរចាលើដីសាលាកាត់ក្តីនៅឡុងប៊ិចនិងដីនៅសាលាក្រុងដើម្បីធានាដល់ការអភិវឌ្ឍន៍នាពេលអនាគតរបស់អគារទាំងពីរ។ ពេលដែលធ្វើការនៅមន្ទីរឧស្ម័ននិងប្រេងនៃឡុងប៊ិចដែលឥឡូវនេះបានផ្លាស់ប្តូរទៅជាមន្ទីរធនធានថាមពលគាត់ជាអ្នកជួយបន្ថែមបច្ចេកវិជ្ជានិងអនុវត្តការអានម៉ែត្រដោយស្វ័យប្រវត្តិ។ ក្នុងនាមជានាយកមន្ទីរសាធារណការលោក Beck បានបង្កើតវប្បធម៌នៃការផ្តល់សេវាកម្មដែលផ្តោតលើអតិថិជន។

លោក Craig Beck បានមានប្រសាសន៍ថា "នៅក្នុងអាជីពរបស់ខ្ញុំខ្ញុំមានឯកសិទ្ធិធ្វើការជាមួយមនុស្សដែលមានទេពកោសល្យនិងមានទឹកចិត្តខ្ពស់ដែលជារៀងរាល់ថ្ងៃបានដាក់ថាមពលរបស់ពួកគាត់ដើម្បីធ្វើឱ្យឡុងប៊ិចក្លាយជាកន្លែងប្រសើរជាងមុនសម្រាប់រស់នៅធ្វើការនិងលេង។ ពួកគាត់បានបង្រៀនខ្ញុំ

ណែនាំខ្ញុំនិងជំរុញខ្ញុំឱ្យរស់នៅស្របតាមស្តង់ដារនៃការលះបង់របស់ពួកគាត់។ ខ្ញុំនឹងនឹកបទពិសោធដែលបានចែករំលែកជាផ្នែកមួយនៃក្រុមថ្នាក់ដឹកនាំនៃទីក្រុងប៉ុន្តែខ្ញុំក៏មានទំនុកចិត្តលើអ្នកដែលធ្វើការរាល់ថ្ងៃដើម្បីធ្វើឱ្យទីក្រុងឡុងប៊ិចក្លាយជាទីក្រុងដ៏អស្ចារ្យមួយ។"

ថ្ងៃចុងក្រោយរបស់លោក Beck គឺថ្ងៃទី ៧ ខែកក្កដាឆ្នាំ ២០២០។ ប្រធានគ្រប់គ្រងក្រុងនឹងធ្វើការជ្រើសរើសបុគ្គលិកផ្ទៃក្នុងសម្រាប់ប្រធានមន្ទីរសាធារណៈការបន្ទាប់ហើយរំពឹងថានឹងប្រកាសប្រធានមន្ទីរសាធារណៈការថ្មីមុនពេលដែលលោក Beck ចាកចេញ។

**អំពីទីក្រុងឡុងប៊ិច**

ជាទីលំនៅដ្ឋាននៃប្រជាជនប្រមាណ ៤៨០,០០០ នាក់ទីក្រុងឡុងប៊ិចបានទទួលពានរង្វាន់និងជាទីក្រុងច្នៃប្រឌិតដែលផ្តល់ជូននូវភាពសំបូរបែបនៃពិភពលោកខណៈពេលដែលរក្សាលក្ខណៈបុគ្គលនិងដែលបង្កើតឡើងពីសង្កាត់ផ្សេងៗពីគ្នាដែលបានផ្តុំនៅតាមបណ្តោយឆ្នេរសមុទ្រប៉ាស៊ីហ្វិក។ ក្នុងនាមជាទីក្រុងដែលមានសេវាកម្មពេញលេញទីក្រុងឡុងប៊ិចជាលំនៅដ្ឋានរបស់នាវា Queen Mary, អាងចិញ្ចឹមត្រីនៃមហាសមុទ្រប៉ាស៊ីហ្វិក (Aquarium of the Pacific), សារមន្ទីរនិងរោងកុនជាច្រើន, សាលារៀនដែលត្រូវបានវាយតម្លៃខ្ពស់, អាកាសយានដ្ឋានឡុងប៊ិច, កំពង់ផែឡុងប៊ិច ក៏ដូចជាមន្ទីរផ្សេងៗដែលបានទទួលពានរង្វាន់ជាច្រើនដូចជាមន្ទីរសុខាភិបាល មន្ទីរឧទ្យានការកំសាន្តនិងសមុទ្រ មន្ទីរសេវាកម្មអភិវឌ្ឍន៍ និងមន្ទីរផ្សេងៗទៀត។ ទីក្រុងនេះក៏មានសាកលវិទ្យាល័យនិងមហាវិទ្យាល័យដែលត្រូវបានការគោរពខ្ពស់ ក៏ដូចជាកន្លែងចិញ្ចឹមសត្វជាប្រវត្តិសាស្ត្រចំនួន២ មន្ទីរពេទ្យ៥ ទីតាំង៥សម្រាប់លេងហ្គោល សួន១៧០ ឆ្នេរសមុទ្រជាច្រើនម៉ាយល៍ម៉ា ផ្លូវសម្រាប់ជិះកង់ និងកម្មវិធីជិះកង់ដែលមានការចែករំលែក។

សម្រាប់ព័ត៌មានបន្ថែមអំពីទីក្រុងឡុងប៊ិចសូមចូលទៅកាន់គេហទំព័រ http://longbeach.gov/។ សូមតាមដានទីក្រុងឡុងប៊ិចនៅលើបណ្តាញសង្គមសម្រាប់ព័ត៌មានថ្មីៗនៅលើ ហ្វេសប៊ុក ធ្វីតធ័រ Instagram និង យូធ្យូប។

# # #